**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៣៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់តំបន់ឧទ្យានជាតិកែប

# រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នសរកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងបរិស្ថាន

-បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី តំបន់ការពារធម្មជាតិ

-បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពី ការកំណត់តំបន់ការពារធម្មជាតិ

-បានឃើញអនុក្រឹត្យលេខ ៥៧អនក្រ/បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

## ស ម្រេ ច

**មាត្រា១៖** ត្រូវបានកែសម្រួលឧទ្យានជាតិកែបពីផ្ទៃដីទំហំ ៥.០០០ហិកតា មកនៅត្រឹមផ្ទៃដីទំហំ ១.១៥២(មួយពាន់មួយរយហាសិបពីរ)ហិកតា ដូចមានកំណត់ក្នុងផែនទី និងនិយាមកាភ្ជាប់មកជាមួយ។

**មាត្រា២៖** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៣៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលខេត្តកែប ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ ៧ ឆ្នាំ ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល៖</u>
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ផែនទីឧទ្យានជាតិ កែប KEP NATIONTAL PARK MAP

ផ្ទៃដីទំហំ ១.១៥២ ហិកតា

អនុក្រឹត្យ លេខ ១៣៧ អនក្រ.បក

ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១០






| ID | N | X | Y | ID | N | X | Y |
|---|---|---|---|---|---|---|---|
| 1 | A | 425387 | 1165148 | 14 | N | 423387 | 1158701 |
| 2 | B | 425519 | 1164067 | 15 | O | 423614 | 1158964 |
| 3 | C | 425964 | 1162965 | 16 | P | 423408 | 1160220 |
| 4 | D | 425841 | 1161785 | 17 | Q | 423443 | 1161134 |
| 5 | E | 426703 | 1161368 | 18 | R | 423436 | 1162246 |
| 6 | F | 425768 | 1160790 | 19 | S | 424143 | 1161559 |
| 7 | G | 425411 | 1160473 | 20 | T | 424251 | 1163189 |
| 8 | H | 424618 | 1159893 | 21 | U | 424453 | 1164139 |
| 9 | I | 424149 | 1160232 | 22 | V | 425226 | 1164474 |
| 10 | J | 424284 | 1159485 | 23 | W | 422967 | 1158471 |
| 11 | K | 424741 | 1159087 | 24 | X | 422731 | 1158311 |
| 12 | L | 424069 | 1158489 | 25 | Y | 422724 | 1159029 |
| 13 | M | 423537 | 1158040 | 26 | Z | 422958 | 1159042 |

សញ្ញាសំគាល់